# ជីវិតកម្មកររោងចក្រ

លំនាំបទ:អណ្តាតម្តាយក្មេក

| | | |
|---|---|---|
| ១. | យើងជាកម្មកររោងចក្រកាត់ដេរ | មិនទំនេរទេធ្វើការរាល់ថ្ងៃ |
| | ខំប្រឹងថែមម៉ោងមិនថាយប់ថ្ងៃ | ព្រោះតែរូបស្រីជាកូនអ្នកក្រ ។ |
| ២. | ប្រាក់ខែដែលបើកបានត្រូវបែងចែក | ជាច្រើនចំណែកឥតមានសល់អ្វី |
| | ជួយសងបំណុលជំនួសម្តាយថ្លៃ | ជីវិតស្ទើរក្ស័យរស់ទាំងត្រដរ ។ |
| បន្ទរ | ណាត្រូវសង្គមមើលងាយប្រមាថ | គេជៀលមាយាទថាស្រីមិនល្អ |
| | រស់ក្នុងអើយ ពិភពអយុត្តិធម៌ | ជីវិតកម្មករឈឺចាប់យ៉ាងណា ។ |
| ៣. | យើងជាកម្មកររួបរួមសាមគ្គី | ត្រូវប្រឹងសំភីដោយចិត្តស្មោះសរ |
| | ខំរើបំរះពីនឹមទាសករ | នោះពិតជាល្អទៅថ្ងៃអនាគត ។ |

ពោល: ក្រោកឡើងណាមិត្ត ត្រូវគិតជាថ្មី ចូរហ៊ានស្រដី រឿងអ្វីដែលពិត យើងចេះរួបរួម
ទោះឆ្ងាយឬជិត ដើម្បីជីវិត មានន័យខ្លឹមសារ ក្រោកឡើង ។